**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខ: ០០៩/១៤ សរ.ជណ.ព ២៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤

ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤ វេលាម៉ោង៨ និង ៣០នាទី នៅវិមានសន្តិភាពមានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៥-២០១៧**

**២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ។**

**៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនិយ័តដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។**

**៤- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា។**

**៥- បញ្ហាផ្សេងៗ**

### ១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៥-២០១៧

ក្រសួងផែនការ បានទទួលការគាំទ្រ និងកិច្ចសហការជិតស្និទ្ធពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដើម្បីរៀបចំ កម្មវិធីវិនិយោគសាធារណៈ(**កវស**) ៣ឆ្នាំរំកិល ២០១៥- ២០១៧ នេះ។

គោលបំណងសំខាន់នៃ កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល២០១៥-២០១៧ គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគ ដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* និងផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង *ផែនការសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨* ហើយត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៤។


ទូរសារលេខ: ០២៣ ២១២ ៤៩០, ទូរស័ព្ទ: ០១២ ៤៤៤ ៩៧៦, ០៩៧ ៧ ៩៧០ ៦០៨
អ៊ីមែល: pressocm@gmail.com

ដើម្បីធ្វើឲ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច (ផសស) ៦-៧% និងអាទិភាពនានាដែលគាំទ្រប្រជាជនក្រីក្រ និងជនបទ ដូចជា ការអភិវឌ្ឍកសិកម្ម និងជនបទ តាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ដូចដែលបានកំណត់រួចមកហើយនៅក្នុង *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣* និង *ផយអជ ២០១៤-២០១៨* ករស ៣ឆ្នាំ រំកិល២០១៥-២០១៧ ត្រូវការទុនសរុប ចំនួន ៥២៤៣ លានដុល្លាអាមេរិកសម្រាប់គម្រោងចំនួន ៥០០ គម្រោងដែលក្នុងនោះធនធាន ៦០ ភាគរយ ត្រូវបន្តវិភាជសម្រាប់ការវិនិយោគនៅតំបន់ជនបទ។

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ។

ចាប់តាំងពីឆ្នាំ ២០១០មក ទោះជាប្រទេសសមាជិកអាស៊ាន៦ បានលុបពន្ធនាំចូលស្ទើរតែទាំងស្រុង ក៏ប៉ុន្តែសង្កេតឃើញថា ពាណិជ្ជកម្មទំនិញក្នុងតំបន់ពុំទាន់បានប្រព្រឹត្តទៅដោយសេរីពេញលេញនៅឡើយ ដោយសារប្រទេសសមាជិកភាគច្រើន បានដាក់វិធានការមិនមែនពន្ធដែលមិនស្របទៅនឹងបទបញ្ញត្តិនានានៃកិច្ចអាស៊ាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន។

កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី១៩ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ ២០១៣ នៅទីក្រុងហាណូយបានសម្រេចឲ្យរដ្ឋសមាជិកនីមួយៗ បង្កើតអង្គភាពអន្តរស្ថាប័នស្តីពីវិធានការមិនមែនពន្ធ ដើម្បីពិនិត្យលើរាល់វិធានការមិនមែនពន្ធនានាដែលបានដាក់ចេញដោយប្រទេសទាំងនោះ ក្នុងគោលបំណងជៀសវាងបាននូវការបង្កើតវិធានការ ដែលផ្ទុយនឹងបទប្បញ្ញត្តិនានាក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន។

គណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធសរសេរជាអក្សរកាត់ថា គ.ជ.ម.ព ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យនេះ នឹងជួយជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មកម្ពុជា និងការបង្កើនល្បឿនសមាហរណកម្ម ទៅក្នុងក្របខណ្ឌតំបន់ពាណិជ្ជកម្មសេរីសំខាន់ៗ ក្នុងតំបន់ ជាពិសេសប្រទេសក្នុងសមាគមន៍អាស៊ាន ស្របតាមទិសដៅឲ្យសម្រេចសហគមន៍អាស៊ានឆ្នាំ ២០១៥ ដូចមានចែងក្នុងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។ ក្រៅពីនោះ នឹងមានការបង្កលក្ខណៈងាយស្រួលឲ្យផលិតផល និងទំនិញធ្វើចរាចរដោយសេរីនៅក្នុងតំបន់ ដោយឈរលើគោលការណ៍ប្រកួតប្រជែងស្មើភាពគ្នា និងតាមតម្លៃទីផ្សារ។

ការអនុវត្តពេញលេញនូវកម្មវិធីការងារនៃវិធានការមិនមែនពន្ធ ដោយប្រទេសសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីដែលកម្ពុជាជាភាគីនឹងធ្វើឲ្យការនាំចេញ ជាពិសេសការនាំចេញកសិផលកម្ពុជា ទៅក្រៅប្រទេសប្រព្រឹត្តទៅដោយរលូន ក្នុងនោះមាននាំចេញពោត និងដំឡូងទៅប្រទេសថៃ ការនាំចេញសន្លឹកថ្នាំជក់ទៅប្រទេសវៀតណាមដោយគ្មានកូតា ព្រមទាំងការនាំចេញទៅប្រទេសដទៃទៀតដែលជាភាគីនៃតំបន់ពាណិជ្ជកម្មសេរីជាមួយអាស៊ាន។

សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការវិធានការមិនមែនពន្ធ មាន៦ ជំពូក ចែកចេញជា ១១មាត្រា ត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។

គោលបំណងនៃសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌ មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម គឺដើម្បីសម្រេចកាតព្វកិច្ចរបស់កម្ពុជា ដូចមានចែងក្នុងផែនការមេរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានត្រង់ចំណុចA1. ស្តីពីលំហូរដោយសេរីទំនិញ និងមាត្រាទី១៣ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន(ASEAN Trade in Goods Agreement- ATIGA) ដែលត្រូវបង្កើតឲ្យបង្កើតនិហិតដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន (ASEAN Trade Repository- ATR) ឲ្យបាននៅឆ្នាំ ២០១៥។ ដើម្បីបង្កើតនិហិតដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន រដ្ឋសមាជិកនីមួយៗ ត្រូវបង្កើតនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម (National Trade Repository- NTR) រៀងៗខ្លួនជាមុនសិន។ គេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធពាណិជ្ជកម្មទាំង១០ នឹងតភ្ជាប់គ្នាដើម្បីបង្កើតនិហិតដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន។ ព័ត៌មានទាំងឡាយដែលត្រូវបញ្ចូលទៅក្នុងនិហិតដ្ឋាននេះ នឹងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការការវិនិយោគក្នុងអាស៊ាន ក៏ដូចជាការធ្វើពាណិជ្ជកម្ម និងវិនិយោគជាមួយប្រទេសដៃគូដែលបានបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយអាស៊ាន។ និហិតដ្ឋាននេះនឹងជួយសម្រួលផងដែរដល់ការធ្វើពាណិជ្ជកម្មជាមួយប្រទេសសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក ដោយសារការបញ្ចូលព័ត៌មានពាក់ព័ន្ធនាំចូលប្រជាជាតិអនុគ្រោះបំផុត និងពន្ធចងដែលបានសម្រេចនៅពេលចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ លើសពីនេះទៀតសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសដែលធនធានមានកម្រិត និងពុំមានបណ្តាញក្រៅប្រទេស ក៏អាចស្វែងរកព័ត៌មានចាំបាច់សម្រាប់អាជីវកម្មរបស់ខ្លួនដែរ។ ព័ត៌មានទាំងឡាយនៅក្នុងនិហិតដ្ឋាននេះមានរួមបញ្ចូលនូវកម្មវិធីបន្ថយ/លុបពន្ធនាំចូលក្រោមតំបន់ពាណិជពា្ជកម្មសេរីនានាដែលកម្ពុជាជាភាគី វិធានការមិនមែនពន្ធ វិធានដើមកំណើតទំនិញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាណិជ្ជកម្ម ច្បាប់និងលិខិតបទដ្ឋានគតិយុត្តគយ ព្រមទាំងព័ត៌មានពាណិជ្ជកម្មផ្សេងៗទៀត។

សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌មានពាក់នឹង ពាណិជ្ជកម្មមាន៦ ជំពូកចែកចេញជា១១មាត្រា។ និហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដែលសរសេរជាអក្សរកាត់ថា **ន.ជ.ព.ព** ដែលបង្កើតឡើងដោយអានុក្រឹត្យនេះស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាពចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៩ នៅរាជធានីភ្នំពេញ ហើយដែលបានចូលជាធរមាននៅថ្ងៃទី ២០ មករា ឆ្នាំ ២០១១។ គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជាដែលសរសេរអក្សរកាត់ថា គ.ស.ន.ម.ក ដែលបង្កើតឡើងតាមរយៈអនុក្រឹត្យនេះនឹងដើរតួជាការ...

សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ឲ្យមានប្រសិទ្ធភាពទោះជាក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគីឬអន្តរជាតិ ធានាដល់ការអភិវឌ្ឍន៍ការដឹកជញ្ជូនតាមផ្លូវទឹក និងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនឲ្យបានល្អប្រសើរឡើង។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជាមាន៦ជំពូក និង១៣មាត្រាត្រូវបានរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

## ៥- បញ្ហាផ្សេងៗ៖

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានមានប្រសាសន៍ណែនាំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជំរុញការរៀបចំសេចក្តីព្រៀងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ឲ្យបានឆាប់រហ័សដើម្បីពិនិត្យ និងសម្រេចដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ ឲ្យបានតាមពេលកំណត់។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២ និង ៣០នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៤